ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ




# សៀវភៅរបាយការណ៍

# លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ

## ខេត្តតាកែវ និងខេត្តកណ្ដាល

**រៀបចំដោយ៖**

នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ

វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ

រាជធានីភ្នំពេញ ខែធ្នូ ឆ្នាំ២០២០

# មាតិកា

**បុព្វកថា** ..... i
**អារម្ភកថា** ..... ii
**ជំពូកទី១** ..... ១
**សេចក្តីផ្តើម** ..... ១
**១.១. សេចក្តីផ្តើម** ..... ២
**១.២. គោលបំណង** ..... ២
**១.៣. វិធីសាស្ត្រប្រមូលទិន្នន័យ** ..... ៣
**១.៤. ការកែច្នៃទិន្នន័យ** ..... ៣
**ជំពូកទី២** ..... ៤
**វិភាគទិន្នន័យ** ..... ៤
**២.១. ព័ត៌មានប្រជាសាស្ត្រ** ..... ៥
២.១.១. ចំនួនប្រជាជន និងគ្រួសារ ..... ៥
២.១.២. ព័ត៌មានប្រជាជន ..... ៦
២.១.៣. ការផ្លាស់ប្តូរទីលំនៅ ..... ៨
២.១.៤. លំនៅឋាន ..... ១១
២.១.៥. សម្ភារៈ ឬបរិក្ខារដឹកជញ្ជូន ..... ១៥
**២.២. អត្រាកំណើត និងមរណភាព** ..... ១៨
២.២.១. អត្រាកំណើត ..... ១៨
២.២.២. មរណភាព ..... ១៩
**២.៣. ពិការភាព** ..... ២២
**២.៤. ការប្រើប្រាស់ទឹក និងអនាម័យ** ..... ២៥
**២.៥. បរិស្ថាន និងធនធានធម្មជាតិ** ..... ២៧
**២.៦. គ្រោះធម្មជាតិ** ..... ៣០
**២.៧. សន្តិសុខសង្គម និងសេដ្ឋកិច្ច** ..... ៣១
២.៧.១. អសន្តិសុខសង្គម ..... ៣១
២.៧.២. សេដ្ឋកិច្ចគ្រួសារ ..... ៣៤
២.៧.៣. ប្រភេទនៃលំហូរវិនិយោគ ..... ៣៩
**២.៨. វិស័យអប់រំ និងសេវាសង្គម** ..... ៤០
២.៨.១. ផ្នែកសិក្សាអប់រំ ..... ៤០

២.៨.២. ផ្នែកសេវាសង្គម ............ ៤២
**២.៩. ផ្លូវគមនាគមន៍ ............ ៤៤**
**២.១០. សុខាភិបាល ............ ៤៥**
២.១០.១. សេវាកម្មសុខភាព ............ ៤៥
២.១០.២. ប្រេវ៉ាឡង់ជំងឺសំខាន់ៗ ............ ៤៧
២.១០.៣. គ្រួសារផ្ទុកមេរោគអេដស៍ ឬជំងឺអេដស៍ និងកុមារកំព្រា ............ ៥១
**២.១១. កសិកម្ម ............ ៥២**
២.១១.១. ការកាន់កាប់ផ្ទៃដីដំដុះ ............ ៥២
២.១១.២. ផ្ទៃដីដាំដុះ និងប្រមូលផល ............ ៥៣
២.១១.៣. ប្រព័ន្ធស្រោចស្រព ............ ៥៤
២.១១.៤. ការប្រើប្រាស់ធាតុចូលក្នុងកសិកម្ម ............ ៥៥
២.១១.៥. ការចិញ្ចឹមបសុសត្វ និងបសុបក្សី ............ ៥៦
**ជំពូកទី៣ ............ ៥៩**
**សន្និដ្ឋាន និងអនុសាសន៍ ............ ៥៩**
**៣.១. សន្និដ្ឋាន ............ ៦០**
**៣.២. អនុសាសន៍ ............ ៦០**
**ឧបសម្ព័ន្ធ ១ ............ ៦១**
**ឧបសម្ព័ន្ធ ២ ............ ៨០**

# មុខកថា

ខ្ញុំមានសេចក្ដីសោមនស្សរីករាយ នឹងបង្ហាញជូនរបាយការណ៍លទ្ធផលវិភាគ ស្ដីពីស្ថិតិថ្នាក់ក្រោមជាតិជំហានទី៤ ដោយផ្អែកលើទិន្នន័យដែលបានប្រមូលចំនួន២ ខេត្ត គឺខេត្តតាកែវ និងខេត្តកណ្ដាល។ របាយការណ៍នេះបានប្រមូលនូវទិន្នន័យសំខាន់ៗរួមមាន៖ ស្ថិតិប្រជាសាស្ត្រ ស្ថិតិកសិកម្ម ស្ថិតិសេដ្ឋកិច្ច និងស្ថិតិសង្គមកិច្ច សម្រាប់ជាមូលដ្ឋានគ្រឹះក្នុងការកសាងផែនការ រៀបចំគោលនយោបាយ និងកម្មវិធីផ្សេងៗ ដើម្បីអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ ស្របតាមកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ។

ខ្ញុំសូមថ្លែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅដល់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានសម្រេចឱ្យក្រសួងផែនការបង្កើតនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ នេះឡើងតាមអនុក្រឹត្យ លេខ៧០ អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ កន្លងមក។

សូមថ្លែងអំណរគុណដល់ ឯកឧត្តម **ហោ ដារិទ្ធ** រដ្ឋលេខាធិការ ក្រសួងផែនការ លោកជំទាវ **ហង់ លីណា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ ដែលបានដឹកនាំ និងសម្របសម្រួលការងារនេះតាំងពីចាប់ផ្ដើម ដោយមានជំនួយការពីឯកឧត្តមបណ្ឌិត **ម៉េង គីមហ៊ី** ឯកឧត្តម **ពេជ ពោធិ** អគ្គនាយករង វិទ្យាស្ថានជាតិស្ថិតិ ទទួលបន្ទុកនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ ឯកឧត្តម **ចាន់ សំអាត** ប្រធាននាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ លោក លោកស្រី អនុប្រធាន នាយកដ្ឋាន ប្រធានការិយាល័យ អនុប្រធានការិយាល័យ ព្រមទាំងមន្ត្រីទាំងអស់ដែលនៅក្នុងនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ។

សូមថ្លែងអំណរគុណដល់ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត ឯកឧត្តម លោក លោកស្រីប្រធានមន្ទីរផែនការខេត្ត និងសហការីនៃខេត្តទាំងពីរ ដូចបានរៀបរាប់ខាងលើ ដែលបានជួយសហការយ៉ាងសកម្មនៅក្នុងអំឡុងពេលចុះស្រង់ទិន្នន័យជាក់ស្តែង។

ខ្ញុំសង្ឃឹមថា អ្នករៀបចំគោលនយោបាយ អ្នកធ្វើផែនការសម្រាប់អភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័ន អង្គការជាតិ អន្តរជាតិ អ្នកស្រាវជ្រាវ និងសាធារណជនទូទៅ នឹងប្រើប្រាស់របាយការណ៍ដ៏មានសារៈសំខាន់នេះ៕

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងផែនការ**

ភ្នំពេញ កម្ពុជា
ខែធ្នូ ឆ្នាំ២០២០

**កិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន**

# អារម្ភកថា

នេះជាការបោះពុម្ពផ្សាយជាលើកទី៣ នៃទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ ដែលបានផលិតឡើង ដោយនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ ដោយមានកិច្ចសហការពីមន្ទីរផែនការខេត្តកណ្តាល និងខេត្តតាកែវ។ សៀវភៅនេះផ្តល់នូវទិន្នន័យរួមមាន៖ ស្ថិតិផ្នែកប្រជាសាស្ត្រ សន្តិសុខសង្គម សេដ្ឋកិច្ចវិស័យ អប់រំ សេវាសង្គម សុខាភិបាល និងផ្នែកកសិកម្ម សម្រាប់យកមកបម្រើការកសាងផែនការ និងរៀបចំគោលនយោបាយ កម្មវិធីផ្សេងៗ ដើម្បីអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ។

ការបោះពុម្ពផ្សាយនេះរួមមានតារាងជាតួលេខ និងក្រាហ្វិក ដែលមានការវិភាគអធិប្បាយខ្លីៗ និងអាចប្រើប្រាស់ជាប្រភពទិន្នន័យ ព័ត៌មានសម្រាប់អ្នកប្រើប្រាស់គ្រប់រូបដែលមានចំណាប់អារម្មណ៍ទៅលើទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ។ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិត្រូវបានផលិតឡើងដំបូងបំផុតដោយនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ សហការជាមួយមន្ទីរផែនការខេត្ត ដែលជំហានទី១ បានចុះស្រង់ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិចំនួន៥ខេត្ត (ខេត្តបន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង និងខេត្តកំពង់ស្ពឺ) ជំហានទី២ បានចំនួន៤ខេត្ត (ខេត្តកែប កំពត កោះកុង និងខេត្តព្រះសីហនុ) និងជំហានទី៣ បានចំនួន៥ខេត្ត (ខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី និងខេត្តព្រះវិហារ)។ នៅជំហានទី៤នេះ ក្រុមការងារចុះស្រង់ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិបានចំនួន២ខេត្ត គឺខេត្តកណ្តាល និងខេត្តតាកែវ។

ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងអរគុណចំពោះក្រុមការងារនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ និងមន្ទីរផែនការខេត្ត ដែលបានចូលរួមចំណែកយ៉ាងធំធេង ក្នុងការរៀបចំចងក្រងបោះពុម្ពនូវទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិដ៏មានសារៈសំខាន់ជាលើកទី៤នេះ៕

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជាអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ**

**ហង់ លីណា**

ភ្នំពេញ កម្ពុជា
ខែធ្នូ ឆ្នាំ២០២០

# ជំពូកទី១

# សេចក្តីផ្តើម

## ១.១. សេចក្តីផ្តើម

គម្រោងគាំទ្រស្ថិតិថ្នាក់ក្រោមជាតិ គឺជាគម្រោងថ្មីមួយដែលវិទ្យាស្ថានជាតិស្ថិតិបានរៀបចំឡើងដើម្បីប្រមូលទិន្នន័យស្ថិតិនៅថ្នាក់មូលដ្ឋាន និងធ្វើការវិភាគលើលទ្ធផលទាំងនោះស្របតាមការធ្វើវិមជ្ឈការ និងសហវិមជ្ឈការសម្រាប់ថ្នាក់ក្រោមជាតិ។

ស្ថិតិដែលត្រូវប្រមូលពីថ្នាក់មូលដ្ឋានដើម្បីយកមកចងក្រងវិភាគរួមមាន៖ ស្ថិតិប្រជាសាស្ត្រ ស្ថិតិកសិកម្ម ស្ថិតិសេដ្ឋកិច្ច និងស្ថិតិសង្គមកិច្ច។ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ គឺជាអ្នកអនុវត្តគម្រោងនេះផ្ទាល់ ដែលស្របតាមភារកិច្ចរបស់នាយកដ្ឋាន និងតាមសេចក្តីសម្រេចដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ស្នើឲ្យបង្កើតនាយកដ្ឋាននេះឡើងតាមអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤។

ប្រទេសកម្ពុជាបានបែងចែកជា៤តំបន់សំខាន់ៗគឺ តំបន់ទំនាបកណ្តាល តំបន់បឹងទន្លេសាប តំបន់ឆ្នេរសមុទ្រ និងតំបន់ភ្នំនិងខ្ពង់រាប។ នៅឆ្នាំ២០១៩ ជំហានទី៤នេះ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ បានជ្រើសរើសខេត្តចំនួន២ ដើម្បីយកមកអនុវត្តគម្រោង គឺខេត្តកណ្តាល និងខេត្តតាកែវ ក្នុងចំណោមរាជធានីខេត្តទាំង២៥របស់ប្រទេសកម្ពុជា ដែលចេញពី រាជធានីភ្នំពេញតាមបណ្តោយផ្លូវជាតិលេខ២១ សម្រាប់ខេត្តកណ្តាល និងតាមផ្លូវជាតិលេខ២ សម្រាប់ខេត្តតាកែវ។

## ១.២. គោលបំណង

គោលបំណងសំខាន់នៃគម្រោងស្ថិតិថ្នាក់ក្រោមជាតិ គឺការវិភាគទិន្នន័យរកឲ្យឃើញនូវបញ្ហាដែលអាចកើតមានឡើងនៅក្នុងមូលដ្ឋាន ដែលមានទិន្នន័យដែលទាក់ទងទៅនឹងព័ត៌មានប្រជាសាស្ត្រ សេដ្ឋកិច្ច សង្គមកិច្ច សេវាសុខាភិបាល អប់រំ និងកសិកម្ម របស់ខេត្តទាំងពីរ (ខេត្តកណ្តាល និងខេត្តតាកែវ)។

## ១.៣. វិធីសាស្ត្រប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យ គឺធ្វើឡើងដោយមន្ត្រីនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ និងមានការចូលរួមពីមន្ត្រីនៃមន្ទីរផែនការខេត្តទាំងពីរផងដែរ ដោយបានប្រើប្រាស់កម្រងបញ្ជីសំណួរស្ថិតិថ្នាក់ក្រោមជាតិ ចុះសម្ភាសប្រធានភូមិដោយផ្ទាល់ គ្រប់ភូមិទាំងអស់ដែលមាននៅក្នុងខេត្តទាំងពីរ រយៈពេល១៥ថ្ងៃ គឺចាប់ពីថ្ងៃទី០៦ ដល់ ២០ ខែមីនា ឆ្នាំ២០១៨។ កាលបរិច្ឆេទយោងគឺរយៈពេល១២ខែកន្លងមក គិតចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨ ដល់ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩។

## ១.៤. ការកែច្នៃទិន្នន័យ

ទិន្នន័យនេះ គឺត្រូវបានធ្វើការកែច្នៃដោយដៃ និងប្រើប្រាស់កម្មវិធី CSPro សម្រាប់វាយបញ្ចូលទៅក្នុងកុំព្យូទ័រ។ កម្មវិធី CSPro, SPSS និង Microsoft Excel ក៏ត្រូវបានប្រើប្រាស់ផងដែរ សម្រាប់ធ្វើការវិភាគទិន្នន័យ បង្កើតជាតារាង និងសង់ជាក្រាប មុននឹងឈានដល់ការបកស្រាយទិន្នន័យ និងវាយអត្ថបទចូលទៅក្នុងកម្មវិធី Microsoft Word។ ការវាយបញ្ចូល និងវិភាគទិន្នន័យមានរយៈពេល០២ខែ គឺចាប់ពីថ្ងៃទី០១ ខែមេសា ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩ បន្ទាប់ពីការចុះស្រង់ទិន្នន័យតាមមូលដ្ឋានរួចមក។

# ជំពូកទី២

# វិភាគទិន្នន័យ

នៅក្នុងរបាយការណ៍នេះ មានទិន្នន័យដែលទាក់ទងទៅនឹងព័ត៌មានប្រជាសាស្ត្រ សន្តិសុខសង្គម សេដ្ឋកិច្ច សង្គមកិច្ច សុខាភិបាល អប់រំ និងផ្នែកកសិកម្ម។

## ២.១. ព័ត៌មានប្រជាសាស្ត្រ

### ២.១.១. ចំនួនប្រជាជន និងគ្រួសារ

ចំនួនគ្រួសារ និងប្រជាជននៅក្នុងខេត្តទាំង២ (ខេត្តកណ្តាល និងខេត្តតាកែវ) មានចំនួនសរុប ៥១៥.៥៧៩គ្រួសារ និងមានប្រជាជនសរុប ២.២៨៣.៣១៩នាក់ (គិតត្រឹមថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩)។

***តារាងទី(១) ចំនួនប្រជាជន និងគ្រួសារ***

| គ្រួសារនិងប្រជាជន | កណ្តាល | តាកែវ | សរុប |
|---|---|---|---|
| គ្រួសារ | ២៨៦,១៧៥ | ២២៩,៤០៤ | ៥១៥,៥៧៩ |
| ប្រជាជន | ១,២៤៣,៣៧២ | ១,០៣៩,៩៤៧ | ២,២៨៣,៣១៩ |

តារាងទី(១) បង្ហាញឱ្យឃើញថា៖ **ខេត្តកណ្តាល** មានគ្រួសារសរុបចំនួន ២៨៦.១៧៥ គ្រួសារ ដែលមានប្រជាជនសរុប ១.២៤៣.៣៧២នាក់។ ចំណែក**ខេត្តតាកែវ** មានប្រជាជនសរុបចំនួន ១.០៣៩.៩៤៧នាក់ ស្មើនឹង ២២៩.៤០៤គ្រួសារ។

*រូបទី(១) ភាគរយស្ត្រីជាមេគ្រួសារ និងមេគ្រួសាជាស្ត្រីដែលមានកូនអាយុក្រោម៥ឆ្នាំ*



រូបទី(១) បានបង្ហាញថា៖ **ខេត្តកណ្ដាល** មានមេគ្រួសារសរុប ២៨៦.១៧៥ ក្នុងនោះមេគ្រួសារជាស្ត្រីមានចំនួន ១៥% និងមាន ១,៦% មានកូនអាយុក្រោម៥ឆ្នាំក្នុងចំណោមគ្រួសារដែលមានស្ត្រីជាមេគ្រួសារទាំងនោះ។ **ខេត្តតាកែវ** ចំណោមមេគ្រួសារសរុប ២២៩.៤០៤ មានមេគ្រួសារជាស្ត្រី ១៩,៤% (២,២% មានកូនអាយុក្រោម៥ឆ្នាំ)។

## ២.១.២. ព័ត៌មានប្រជាជន

### ក. គ្រួសារតាមជនជាតិ

*រូបទី(២) ភាគរយគ្រួសារតាមជនជាតិ*




រូបទី(២) បានបង្ហាញថា៖ ចំណោមគ្រួសារសរុបទាំងពីរខេត្ត (ក្នុងនោះមិនរាប់បញ្ចូលភាគរយគ្រួសារដែលជាជនជាតិខ្មែរទេ គឺយកតែភាគរយនៃគ្រួសារជនជាតិផ្សេងប៉ុណ្ណោះ) រួមមាន៖ **ខេត្តកណ្ដាល** ដែលមានគ្រួសារសរុប ២៨៦.១៧៥ ក្រៅពីគ្រួសារដែលជាជនជាតិខ្មែរក៏នៅមានគ្រួសារដែលជាជនជាតិផ្សេងរស់នៅផងដែរ គឺមានគ្រួសារជនជាតិខ្មែរឥស្លាម ១,៣០% គ្រួសារជនជាតិវៀតណាម ១,២៩% និងគ្រួសារជនជាតិឡាវ ០,០១%។ **ខេត្តតាកែវ** មានគ្រួសារសរុប ២២៩.៤០៤ ក្រៅពីគ្រួសារដែលជាជនជាតិខ្មែររស់នៅ ក៏នៅមានគ្រួសារជនជាតិផ្សេងចំនួនពីរទៀត គឺខ្មែរឥស្លាមមាន០,៦៤% និងវៀតណាមមាន ០,០៦%។

## ខ. ស្ថានភាពអាពាហ៍ពិពាហ៍របស់មេគ្រួសារ

*រូបទី(៣) ភាគរយមេគ្រួសារតាមស្ថានភាពអាពាហ៍ពិពាហ៍*




រូបទី(៣) បានបង្ហាញថា៖ ខេត្តទាំងពីរមានភាគរយស្ថានភាពអាពាហ៍ពិពាហ៍របស់មេគ្រួសារសរុបស្ទើរតែប្រហាក់ប្រហែលគ្នា ដែលរួមមាន៖ **ខេត្តកណ្តាល** មានមេគ្រួសារសរុប ២៨៦.១៧៥ ក្នុងនោះមានមេគ្រួសារដែលបានរៀបការរស់នៅជាមួយគ្នា ៨២% ខុសឆ្ងាយពីមេគ្រួសាររស់នៅផ្សេងគ្នាដែលមានត្រឹមតែ ០,៦%។ ចំណែកមេគ្រួសារមេម៉ាយ/ពោះម៉ាយមាន ១៥.៦% ហើយមេគ្រួសារដែលរស់នៅជាមួយគ្នាមិនបានរៀបការមាន ១%។ ទន្ទឹមនោះក៏នៅមាន ០,៨% ទៀតដែលជាគ្រួសារដែលមានមេគ្រួសារមិនដែលរៀបការ។ **ខេត្តតាកែវ** មានមេគ្រួសារសរុប ២២៩.៤០៤ ក្នុងនោះយើងឃើញថា មេគ្រួសារដែលបានរៀបការរស់នៅជាមួយគ្នាគឺមានភាគរយខ្ពស់ជាងគេរហូតដល់ ៨១,៨% ខុសឆ្ងាយពីមេគ្រួសាររស់នៅជាមួយគ្នាមិនបានរៀបការដែលមានត្រឹមតែ ០,៤% ដែលជាភាគរយទាបជាងគេបំផុតក្នុងចំណោមមេគ្រួសារផ្សេងទៀត។ ទន្ទឹមនឹងនោះ ក៏មានមេគ្រួសារមេម៉ាយ/ពោះម៉ាយ ១៦.៥% និងមេគ្រួសាររស់នៅផ្សេងគ្នា ០,៩%។ ក្រៅពីនោះ ក៏នៅមាន ០,៥% ទៀតដែលជាគ្រួសារដែលមានមេគ្រួសារមិនដែលរៀបការសោះ។

## ២.១.៣. ការផ្លាស់ប្តូរទីលំនៅ

### ក. គ្រួសារធ្វើចំណាកស្រុកចេញ និងចូល

*រូបទី(៥) គ្រួសារធ្វើការផ្លាស់ប្តូរទីលំនៅ*




រូបទី(៥) បានបង្ហាញថា៖ ស្ថានភាពការធ្វើអន្តោប្រវេសន៍របស់គ្រួសារចំណោមគ្រួសារសរុបគ្រប់ខេត្ត រួមមាន៖ **ខេត្តកណ្តាល** ដែលមានគ្រួសារសរុប ២៨៦.១៧៥ ក្នុងនោះមានគ្រួសារធ្វើចំណាកស្រុកចេញស្មើ ៧.២៦១គ្រួសារ និងគ្រួសារធ្វើចំណូលស្រុកស្មើនឹង ២១.៣៣៨គ្រួសារ។ **ខេត្តតាកែវ** មានគ្រួសារសរុប ២២៩.៤០៤ ក្នុងនោះមានគ្រួសារធ្វើចំណាកស្រុកចេញស្មើ ៤.៨៣៥ គ្រួសារ និងគ្រួសារធ្វើចំណូលស្រុកស្មើនឹង ២.៨៦៧គ្រួសារ។

### ខ. មូលហេតុគ្រួសារធ្វើចំណាកស្រុកក្នុង និងក្រៅប្រទេស

*រូបទី(៦) ចំនួនគ្រួសារស្វែងទៅរកការងារធ្វើក្នុងប្រទេស និងក្រៅប្រទេស*



រូបទី(៦) បានបង្ហាញថា៖ ស្ថានភាពការធ្វើអន្តោប្រវេសន៍របស់គ្រួសារចំណោមគ្រួសារសរុបគ្រប់ខេត្ត រួមមាន៖ **ខេត្តកណ្តាល** ដែលមានគ្រួសារសរុប ២៨៦.១៧៥ ក្នុងនោះមានគ្រួសារដែលស្វែងរកការងារនៅក្នុងប្រទេស ១៦.៤៣០គ្រួសារ និងគ្រួសារដែលស្វែងរកការងារនៅក្រៅប្រទេសមាន ៥.១៣០គ្រួសារ។ **ខេត្តតាកែវ** មានគ្រួសារសរុប ២២៩.៤០៤ ក្នុងនោះមានគ្រួសារដែលស្វែងរកការងារនៅក្នុងប្រទេស ១៩.០០៨គ្រួសារ និងគ្រួសារដែលស្វែងរកការងារនៅក្រៅប្រទេសមាន ៧.០២២គ្រួសារ។

### គ. ពលករចំណាកស្រុកក្នុង និងក្រៅប្រទេស

***តារាងទី(២) ចំនួនអ្នកធ្វើចំណាកស្រុកក្នុង និងក្រៅប្រទេស***

| ពលករចំណាកស្រុក | កណ្តាល | តាកែវ |
|---|---|---|
| ក្នុងប្រទេស | ៣៧.៩៤៣ | ៦០.២៧៤ |
| ក្រៅប្រទេស | ៨.៥៤៧ | ២០.៣៧៣ |
| **សរុប** | **៤៦.៤៩០** | **៨០.៦៤៧** |

តារាងទី(២) បានបង្ហាញអំពី៖ ស្ថានភាពពលករចំណាកស្រុកក្នុង និងក្រៅប្រទេស រួមមាន៖ **ខេត្តកណ្តាល** មានគ្រួសារសរុបចំនួន ២៨៦.១៧៥គ្រួសារ និងមានប្រជាជនសរុបចំនួន ១.២៤៣.៣៧២នាក់ នៅចំណោមប្រជាជនសរុបទាំងនោះគឺមាន ៤៦.៤៩០នាក់ ជាពលករ ដែលក្នុងនោះមានពលករធ្វើការងារនៅក្នុងប្រទេសចំនួន ៣៧.៩៤៣នាក់ និងពលករធ្វើការងារនៅក្រៅប្រទេសចំនួន ៨.៥៤៧នាក់។ ចំណែកឯ **ខេត្តតាកែវ** មានគ្រួសារសរុបចំនួន ២២៩.៤០៤គ្រួសារ និងមានប្រជាជនសរុបចំនួន ១.០៣៩.៩៤៧នាក់ នៅចំណោមប្រជាជនសរុបទាំងនោះគឺមាន ៨០.៦៤៧នាក់ ជាពលករ ដែលក្នុងនោះមានពលករធ្វើការងារនៅក្នុងប្រទេសចំនួន ៦០.២៧៤នាក់ និងពលករធ្វើការងារនៅក្រៅប្រទេសចំនួន ២០.៣៧៣នាក់ ។

### ឃ. ពលករស្វែងរកការងារក្នុង និងក្រៅប្រទេសបែងចែកតាមភេទ

#### ឃ.១. ក្នុងប្រទេស




រូបទី(៧) បានបង្ហាញថា៖ ស្ថានភាពពលករចំណាកស្រុកដើម្បីស្វែងរកការងារនៅក្នុងប្រទេស របស់**ខេត្តកណ្ដាល** ដែលមានភាគរយជាពលការីនីស្មើនឹង ៤៧,៦% ក្នុងចំណោមពលករសរុប ៣៧.៩៤៣នាក់។ ឯ**ខេត្តតាកែវ** មានភាគរយជាពលការីនីស្មើនឹង ៥៣% ក្នុងចំណោមពលករសរុប ៨០.៦៤៧នាក់។

#### ឃ.២. ក្រៅប្រទេស




រូបទី(៨) បានបង្ហាញថា៖ ស្ថានភាពពលករចំណាកស្រុកដើម្បីស្វែងរកការងារនៅក្រៅប្រទេសរបស់**ខេត្តកណ្ដាល** ដែលមានភាគរយជាពលការីនីស្មើនឹង ៤៤,៩% ក្នុងចំណោមពលករសរុប ៣៧.៩៤៣នាក់។ ឯ**ខេត្តតាកែវ** មានភាគរយជាពលការីនីស្មើនឹង ៤៣.៦% ក្នុងចំណោមពលករសរុប ៨០.៦៤៧ នាក់។

## ២.១.៤. លំនៅឋាន

### ក. ប្រភេទនៃដំបូលផ្ទះតាមគ្រួសារ

*តារាងទី(៣) ប្រភេទនៃដំបូលផ្ទះ*

| ប្រភេទនៃដំបូលផ្ទះ | កណ្តាល | | តាកែវ | |
|---|---|---|---|---|
| | ចំនួន | % | ចំនួន | % |
| ផ្ទះដំបូលបេតុង | ២០.២៨៧ | ៧,៦៤ | ៦.៨៦១ | ៣,២៥ |
| ផ្ទះដំបូលក្បឿង | ៩៧.៦៤៣ | ៣៦,៧៨ | ១០៨.៤០៩ | ៥១,៣៤ |
| ផ្ទះដំបូលស័ង្កសី/ហ្វីប្រូ | ១៣៥.៩៧៣ | ៥១,២២ | ៨៩.៦២៣ | ៤២,៤៤ |
| ផ្ទះប្រក់ស្លឹក | ៧៣២ | ០,២៨ | ២.១៦៧ | ១,០២ |
| ផ្សេងៗ | ១០.៨៤៤ | ៤,០៨ | ៤.១១១ | ១,៩៥ |
| **សរុប** | **២៦៥.៤៧៩** | **១០០** | **២១១.១៧១** | **១០០** |

តារាងទី(៣) បានបង្ហាញពីភាគរយនៃដំបូលផ្ទះរបស់ប្រជាពលរដ្ឋតាមខេត្តនីមួយៗ ហើយបើមើលទៅលើ**ខេត្តកណ្តាល** មានខ្នងផ្ទះសរុប ២៦៥.៤៧៩ខ្នងផ្ទះ ក្នុងនោះផ្ទះដំបូលប្រក់អំពីស័ង្កសី/ហ្វីប្រូ មានចំនួន ១៣៥.៩៧៣ខ្នងផ្ទះ ស្មើនឹង ៥១,២២% ដែលជាភាគរយខ្ពស់ជាងគេ រីឯផ្ទះដែលមានដំបូលប្រក់ស្លឹកមានត្រឹមតែ ៧៣២ខ្នងផ្ទះ ស្មើនឹង ០,២៨% ដែលជាភាគរយទាបជាងគេបំផុតក្នុងចំណោមផ្ទះប្រក់ដំបូលផ្សេងទៀត។ ទន្ទឹមនឹងនោះក៏នៅមានផ្ទះប្រក់ដំបូលក្បឿង ៩៧.៦៤៣ខ្នងផ្ទះ ស្មើនឹង ៣៦,៧៨% ដំបូលបេតុង ២០.២៨៧ខ្នងផ្ទះ ស្មើនឹង ៧,៦៤% និងផ្ទះប្រក់ដំបូលផ្សេងទៀត ១០.៨៤៤ខ្នងផ្ទះ ដែលស្មើនឹង ៤,០៨%។ **ខេត្តតាកែវ** មានខ្នងផ្ទះសរុប ២១១.១៧១ខ្នងផ្ទះ ក្នុងនោះផ្ទះដំបូលប្រក់អំពីក្បឿងមានចំនួន ១០៨.៤០៩ខ្នងផ្ទះ ស្មើនឹង ៥១,៣៤% ដែលជាភាគរយខ្ពស់ជាងគេ រីឯផ្ទះដែលមានដំបូលប្រក់ស្លឹកមានត្រឹមតែ ២.១៦៧ខ្នងផ្ទះ ស្មើនឹង ១,០២% ដែលជាភាគរយទាបជាងគេបំផុតក្នុងចំណោមផ្ទះប្រក់ដំបូលផ្សេងទៀត។ ទន្ទឹមនឹងនោះក៏នៅមានផ្ទះប្រក់ដំបូលស័ង្កសី/ហ្វីប្រូ ៨៩.៦២៣ខ្នងផ្ទះ ស្មើនឹង ៤២,៤៤% ដំបូលបេតុង ៦.៨៦១ខ្នងផ្ទះ ស្មើនឹង ៣,២៥% និងផ្ទះប្រក់ដំបូលផ្សេងទៀត ៤.១១១ខ្នងផ្ទះ ដែលស្មើនឹង ១,៩៥%។

## ខ. ការប្រើប្រាស់អគ្គិសនីតាមដំបូលផ្ទះ

*រូបទី(៩) ភាគរយគ្រួសារមានអគ្គិសនីប្រើប្រាស់តាមប្រភេទនៃដំបូលផ្ទះ*




រូបទី(៩) បានបង្ហាញអំពីស្ថានភាពការប្រើប្រាស់អគ្គិសនីនៃខេត្តទាំង២តាមប្រភេទដំបូលផ្ទះតាមគ្រួសារនីមួយៗ៖ ជាក់ស្តែងនៅ**ខេត្តកណ្តាល** ផ្ទះដំបូលប្រក់ស័ង្កសី/ហ្វីប្រូមានអគ្គិសនីប្រើប្រាស់ ៤៩,៩៨% និង ៥១,៧៨% ជាផ្ទះដំបូលប្រក់ក្បឿង សម្រាប់**ខេត្តតាកែវ** ដែលជាភាគរយខ្ពស់ជាងគេក្នុងចំណោមផ្ទះដែលមានភ្លើងអគ្គិសនីប្រើប្រាស់ទាំងអស់។ ចំណែកឯគ្រួសារដែលជាភាគរយទាបក្នុងចំណោមខ្នងផ្ទះទាំងអស់វិញក៏មានភ្លើងអគ្គិសនីប្រើប្រាស់ដែរ គឺផ្ទះដែលមានដំបូលប្រក់អំពីស្លឹកមាន ០,២៩% សម្រាប់**ខេត្តកណ្តាល** និង ០,៧៤% សម្រាប់**ខេត្តតាកែវ**។ យើងសង្កេតឃើញថា ភ្លើងអគ្គិសនីគឺទទួលបានស្ទើរតែគ្រប់ខ្នងផ្ទះសម្រាប់ប្រើប្រាស់។ នេះសរបញ្ជាក់ឱ្យឃើញថា វិស័យអគ្គិសនីនៅក្នុងខេត្តទាំងពីរគឺបាននិងកំពុងមានការអភិវឌ្ឍជាខ្លាំង។

## គ. ការប្រើប្រាស់ទូរទស្សន៍តាមដំបូលផ្ទះ

រូបទី(១០) បានបង្ហាញថា៖ ការប្រើប្រាស់ទូរទស្សន៍នៅតាមផ្ទះ គឺមានការស្របជាមួយនឹងការប្រើប្រាស់អគ្គិសនីតាមផ្ទះផងដែរ។ **ខេត្តតាកែវ** ភាគរយដែលខ្ពស់ជាងគេនៃការប្រើប្រាស់ទូរទស្សន៍ គឺផ្ទះដែលមានដំបូលប្រក់អំពីក្បឿង ៥២,៤៦% ឯគ្រួសារដែលមានផ្ទះដំបូលប្រក់អំពីស្លឹកវិញមានតែ ០,៦០% ប៉ុណ្ណោះ ដែលជាភាគរយតិចជាងគេ។ ដោយឡែកនៅ**ខេត្តកណ្តាល** ផ្ទះដំបូលប្រក់អំពីស័ង្កសី/ហ្វីប្រូមានភាគរយខ្ពស់ ៤៩,៥៨% ហើយសូម្បីតែគ្រួសារដំបូលប្រក់អំពីស្លឹកក៏មានទូរទស្សន៍ប្រើប្រាស់ ០,២២%ដែរ។ នេះសរបញ្ជាក់ឲ្យឃើញថា កាលណាវិស័យអគ្គិសនីមានការអភិវឌ្ឍ វានាំឲ្យមានការប្រើប្រាស់ឧបករណ៍ប្រើអគ្គិសនីក៏មានការកើនឡើងផងដែរ។

រូបទី( ១០ ) ភាគរយនៃគ្រួសារមានទូរទស្សន៍ប្រើប្រាស់តាមប្រភេទនៃដំបូលផ្ទះ




## ឃ. ការប្រើប្រាស់កុំព្យូទ័រតាមដំបូលផ្ទះ

រូបទី( ១១ ) ភាគរយនៃគ្រួសារមានកុំព្យូទ័រប្រើប្រាស់តាមប្រភេទនៃដំបូលផ្ទះ




រូបទី(១១) បានបង្ហាញថា៖ ស្ថានភាពគ្រួសារដែលបានប្រើប្រាស់កុំព្យូទ័រស្រដៀងគ្នានឹងគ្រួសារដែលមានអគ្គិសនីប្រើប្រាស់នៅតាមខេត្តទាំង២ផងដែរ។ កុំព្យូទ័រ មានការប្រើប្រាស់ភាគច្រើនចំ ពោះគ្រួសារដែលមានផ្ទះដំបូលប្រក់អំពីក្បឿង ដែលមាន ៥៦,៦១% ក្នុង**ខេត្តតាកែវ** និង ៣៦,០៧% សម្រាប់**ខេត្តកណ្ដាល**។ ឯគ្រួសារដែលមានផ្ទះដំបូលប្រក់អំពីស័ង្កសី/ហ្វីប្រូ គឺបានឈរនៅលេខរៀងបន្ទាប់ ដែលមាន ៣៣,៥៧% ក្នុង**ខេត្តតាកែវ** និង ៣៣,១១% សម្រាប់**ខេត្តកណ្ដាល**។

## ង. ការប្រើប្រាស់ទូរសព្ទដៃតាមដំបូលផ្ទះ

*រូបទី(១២) ភាគរយនៃគ្រួសារមានទូរសព្ទដៃប្រើប្រាស់តាមប្រភេទនៃដំបូលផ្ទះ*




រូបទី(១២) បានបង្ហាញពីភាគរយនៃការប្រើប្រាស់ទូរសព្ទទៅតាមប្រភេទនៃដំបូលផ្ទះរបស់ប្រជាពលរដ្ឋតាមបណ្ដាខេត្តទាំង២។ **ខេត្តតាកែវ** មាន៥២,៥៣% ជាផ្ទះដំបូលប្រក់អំពីក្បឿង ហើយ **ខេត្តកណ្ដាល** មាន ៥១,០៥% ជាផ្ទះដំបូលប្រក់ស័ង្កសី/ហ្វីប្រូ ដែលជាភាគរយនៃផ្ទះដែលមានទូរសព្ទដៃប្រើប្រាស់ច្រើនជាងគេ។ ដោយឡែកនៅខេត្តទាំងពីរយើងក៏សង្កេតឃើញមានផងដែរថា ផ្ទះដែលដំបូលប្រក់ស្លឹក គឺមានភាគរយតិចជាងគេបំផុតក្នុងចំណោមផ្ទះប្រក់ដំបូលផ្សេងៗឯទៀតដែលមាន ទូរសព្ទដៃប្រើប្រាស់ (**ខេត្តតាកែវ** មាន ១,០៧% និង**ខេត្តកណ្ដាល** មាន ០,១៩%)។ ដូចនេះសរបញ្ជាក់ឱ្យឃើញថា វិស័យសេវាទូរគមនាគមន៍នៅក្នុងខេត្តទាំងពីរមានការរីកចម្រើនគួរឱ្យកត់សម្គាល់។

## ២.១.៥. សម្ភារៈ ឬបរិក្ខារដឹកជញ្ជូន

***តារាងទី(៤) ប្រភេទបរិក្ខារតាមប្រភេទ***

| ប្រភេទនៃបរិក្ខារ | កណ្ដាល | | តាកែវ | |
|---|---|---|---|---|
| | ចំនួន | % | ចំនួន | % |
| កសិកម្ម និងនេសាទ | ២៥.៨៨៧ | ៨,០៤ | ៣៥.០៩៥ | ១៣,៨២ |
| សេវាដឹកជញ្ជូន | ២២.៣០៦ | ៦,៩២ | ១២.៥៩៦ | ៤,៩៦ |
| មធ្យោបាយប្រើប្រាស់ផ្ទាល់ខ្លួន | ២៧៣.៩៤២ | ៨៥,០៤ | ២០៦.១៩១ | ៨១,២២ |
| **សរុប** | **៣២២.១៣៥** | **១០០** | **២៥៣.៨៨២** | **១០០** |

តារាងទី(៤) បានបង្ហាញពីភាគរយនៃប្រភេទបរិក្ខារដែលទាក់ទងនឹងគ្រឿងម៉ាស៊ីន និងយានយន្តរបស់ប្រជាពលរដ្ឋតាមខេត្តទាំង២៖ ចំពោះ**ខេត្តកណ្ដាល** មានបរិក្ខារសរុបចំនួន ៣២២.១៣៥ គ្រឿង ដែលរួមមានបរិក្ខារសម្រាប់ធ្វើកសិកម្មនិងនេសាទចំនួន ២៥.៨៨៧គ្រឿង ស្មើនឹង ៨,០៤% សេវាដឹកជញ្ជូនមាន ២២.៣០៦គ្រឿង ស្មើនឹង ៦,៩២% និងបរិក្ខារដែលបម្រើឱ្យមធ្យោបាយប្រើប្រាស់ និងធ្វើដំណើរផ្ទាល់ខ្លួនមានចំនួន ២៧៣.៩៤២គ្រឿង ស្មើនឹង ៨៥,០៤%។ **ខេត្តតាកែវ** មានបរិក្ខារសរុបចំនួន ២៥៣.៨៨២គ្រឿង ដែលរួមមានបរិក្ខារសម្រាប់ធ្វើកសិកម្មនិងនេសាទចំនួន ៣៥.០៩៥គ្រឿង ស្មើនឹង ១៣,៨២% សេវាដឹកជញ្ជូនមាន ១២.៥៩៦គ្រឿង ស្មើនឹង ៤,៩៦% និងបរិក្ខារដែលបម្រើឱ្យមធ្យោបាយប្រើប្រាស់ និងធ្វើដំណើរផ្ទាល់ខ្លួនមានចំនួន ២០៦.១៩១គ្រឿង ស្មើនឹង ៨១,២២%។

### ក. បរិក្ខារកសិកម្ម និងនេសាទ

*រូបទី(១៣) ភាគរយប្រភេទនៃបរិក្ខារកសិកម្ម និងនេសាទ*



រូបទី(១៣) បានបង្ហាញពីភាគរយនៃបរិក្ខារកសិកម្ម និងនេសាទ ដែលរួមមាន៖ **ខេត្តកណ្តាល** មានចំនួន ២៥.៨៨៧គ្រឿង ស្មើនឹង ៨,០៤% នៃប្រភេទបរិក្ខារសរុបរបស់ខេត្ត ក្នុងនោះទូកនេសាទមាន ៤៨,១៩% ដែលជាភាគរយច្រើនជាងគេ បន្ទាប់គឺឧបករណ៍កសិកម្មនិងគ្រឿងម៉ាស៊ីនភ្ជួររាស់មាន ៣០,៨០% ភាគរយបន្តទៀតគឺឧបករណ៍កសិកម្មផ្សេងទៀតមាន ៩,៧១% ឯរទេះគោនិងរទេះសេះមាន ៩,១១% ហើយភាគរយចុងក្រោយគឺម៉ាស៊ីនប្រមូលផលច្រូតកាត់មាន ២,១៩%។ **ខេត្តតាកែវ** មានចំនួន ៣៥.០៩៥គ្រឿង ស្មើនឹង ១៣,៨២% ក្នុងនោះឧបករណ៍កសិកម្មនិងគ្រឿងម៉ាស៊ីនភ្ជួររាស់មាន ៦១,៥៣% ដែលជាភាគរយច្រើនជាងគេ បន្ទាប់គឺទូកនេសាទមាន ១៤,១៣% ភាគរយបន្តទៀតគឺឧបករណ៍កសិកម្មផ្សេងទៀតមាន ១១,៣៧% ឯរទេះគោនិងរទេះសេះមាន ១០,១៨% ហើយភាគរយចុងក្រោយគឺម៉ាស៊ីនប្រមូលផលច្រូតកាត់មាន ២,៧៩%។

### ខ. បរិក្ខារសេវាដឹកជញ្ជូន

*រូបទី(១៤) ភាគរយនៃប្រភេទបរិក្ខារសេវាដឹកជញ្ជូន*




រូបទី(១៤) បានបង្ហាញពីភាគរយនៃបរិក្ខារសេវាដឹកជញ្ជូន ដែលរួមមាន៖ **ខេត្តកណ្តាល** មានចំនួន ២២.៣០៦គ្រឿង ស្មើនឹង ៦,៩២% នៃប្រភេទបរិក្ខារសរុបរបស់ខេត្ត ក្នុងនោះទូកមាន ៥៤,៩៥% ដែលជាភាគរយច្រើនជាងគេ បន្ទាប់គឺម៉ូតូកង់បីមាន ២០,៥% ភាគរយបន្ទាប់ទៀតគឺរថយន្តដឹកទំនិញមាន ១៥,៩% ឯរថយន្តដឹកអ្នកដំណើរ (តាក់ស៊ី និង១២កៅអី) មាន ៧,៦៧% ចំណែករថយន្តក្រុងមាន ០.៥៧ ហើយភាគរយចុងក្រោយគឺទូកដឹកអ្នកដំណើរមាន ០,៤១%។ **ខេត្តតាកែវ** មានចំនួន ១២.៥៩៦គ្រឿង ស្មើនឹង ៤,៩៦% ក្នុងនោះទូកមាន ៣៧,៧៣% ដែលជាភាគរយច្រើនជាងគេ បន្ទាប់គឺរថយន្តដឹកទំនិញមាន ២៤,៣៧% ភាគរយបន្ទាប់ទៀតគឺម៉ូតូកង់បី

មាន ២២,៧៩% ឯរថយន្តដឹកអ្នកដំណើរ (តាក់ស៊ី និង១២កៅអី) មាន ១៣,២៧% ចំណែករថយន្តក្រុងមាន ១.០២ ហើយភាគរយចុងក្រោយគឺទូកដឹកអ្នកដំណើរមាន ០,៨២%។

### គ. បរិក្ខារសេវាដឹកជញ្ជូន និងសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន




រូបទី(១៥) បានបង្ហាញពីភាគរយនៃបរិក្ខារដែលបម្រើឱ្យមធ្យោបាយប្រើប្រាស់ និងធ្វើដំណើរផ្ទាល់ខ្លួន ដែលរួមមាន៖ **ខេត្តកណ្តាល** មានចំនួន ២៧៣.៩៤២គ្រឿង ស្មើនឹង ៨៥,០៤% នៃប្រភេទបរិក្ខារសរុបរបស់ខេត្ត ក្នុងនោះម៉ូតូមាន ៩០,៦១% ដែលជាភាគរយច្រើនជាងគេ បន្ទាប់គឺរថយន្ត លក្ខណៈគ្រួសារមាន ៦,៩% បន្ទាប់មកទៀតគឺរទេះអូសដោយដៃមាន ១,៩៥% និងផ្សេងៗទៀតមាន ០,៥៤% ដែលជាភាគរយចុងក្រោយ។ **ខេត្តតាកែវ** មានចំនួន ២០៦.១៩១គ្រឿង ស្មើនឹង ៨១,២២% នៃប្រភេទបរិក្ខារសរុបរបស់ខេត្ត ក្នុងនោះម៉ូតូមាន ៨៩,៨២% ដែលជាភាគរយច្រើនជាងគេ បន្ទាប់គឺរទេះអូសដោយដៃមាន ៥,៣៦% បន្ទាប់មកទៀតគឺរថយន្តលក្ខណៈគ្រួសារមាន ៤,៥៥% និងផ្សេងៗទៀតមាន ០,២៧% ដែលភាគរយចុងក្រោយ។

## ២.២. អត្រាកំណើត និងមរណភាព

### ២.២.១. អត្រាកំណើត

#### ក. ទីកំណើតទារក

*តារាងទី(៥) កន្លែងទារកកើតក្នុងរយៈពេល១២ខែកន្លងមក*

| ទីកន្លែងកើត | កណ្ដាល | | តាកែវ | |
|---|---|---|---|---|
| | ចំនួន | % | ចំនួន | % |
| មន្ទីរពេទ្យរដ្ឋ | ១២.២៣៤ | ៨៣,៦៩ | ១១.០៨៦ | ៧០,០៤ |
| មន្ទីរពេទ្យឯកជន | ២.០៧៤ | ១៤,១៩ | ៤.៥៩៧ | ២៩,០៤ |
| ឆ្មបបុរាណ | ១២៣ | ០,៨៤ | ១៤ | ០,០៩ |
| ផ្សេងទៀត | ១៨៨ | ១,២៨ | ១៣១ | ០,៨៣ |
| **សរុប** | **១៤.៦១៩** | **១០០** | **១៥.៨២៨** | **១០០** |

តារាងទី(៥) បានបង្ហាញពីភាគរយរបស់ទារកកើតក្នុងរយៈពេល១២ខែកន្លងមក ដែលមាន៖ **ខេត្តកណ្ដាល** មានទារកកើតសរុប ១៤.៦១៩នាក់ ក្នុងនោះមានកើតដោយមន្ទីរពេទ្យរដ្ឋ ១២.២៣៤ នាក់ ស្មើនឹង ៨៣,៦៩% មន្ទីរពេទ្យឯកជន ២.០៧៤នាក់ ស្មើនឹង ១៤,១៩% ឆ្មបបុរាណ ១២៣ នាក់ ស្មើនឹង ០,៨៤% និងកើតដោយមធ្យោបាយផ្សេងៗទៀត ១៨៨នាក់ ស្មើនឹង ១,២៨%។ **ខេត្តតាកែវ** មានទារកកើតសរុប ១៥.៨២៨នាក់ ក្នុងនោះមានកើតដោយមន្ទីរពេទ្យរដ្ឋ ១១.០៨៦នាក់ ស្មើនឹង ៧០,០៤% មន្ទីរពេទ្យឯកជន ៤.៥៩៧នាក់ ស្មើនឹង ២៩,០៤% ឆ្មបបុរាណ ១៤នាក់ ស្មើនឹង ០,០៩% និងកើតដោយមធ្យោបាយផ្សេងៗទៀត ១៣១នាក់ ស្មើនឹង ០,៨៣%។

#### ខ. ភេទនៃទារកកើត

រូបទី(១៦) បានបង្ហាញថា៖ រយៈពេល១២ខែកន្លងមក នៅក្នុងខេត្តទាំង២ មានអត្រាកំណើតទារកភេទប្រុស និងទារកភេទស្រីស្ទើរតែប្រហាក់ប្រហែលគ្នា តែបើនិយាយពីតាមខេត្តនីមួយៗវិញ ឃើញថា អត្រាភាគរយនៃទារកភេទស្រី គឺមានការកើតខ្ពស់ជាងទារកភេទប្រុស។ យ៉ាងណាមិញ ក្នុង**ខេត្តកណ្ដាល** មានទារកភេទស្រីចំនួន ៥១,៧% និងទារកភេទប្រុសចំនួន ៤៨,៣% ហើយ**ខេត្តតាកែវ** មានទារកភេទស្រីចំនួន ៥០,៥% និងទារកភេទប្រុសចំនួន ៤៩,៥%។




## ២.២.២. មរណភាព

### ក. មូលហេតុនៃការស្លាប់

***តារាងទី(៦) មូលហេតុនៃការស្លាប់រយៈពេល១២ខែកន្លងមក***

| មូលហេតុនៃការស្លាប់ | កណ្តាល | | | តាកែវ | | |
|---|---|---|---|---|---|---|
| | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី |
| ជំងឺ | ៤.២៤២ | ២.១៩១ | ២.០៥១ | ៤.២១៧ | ២.១៣៤ | ២.០៨៣ |
| គ្រោះថ្នាក់ចរាចរណ៍ | ៤៣៨ | ៣៣៥ | ១០៣ | ២៧៨ | ២១២ | ៦៦ |
| លង់ទឹក | ៨៧ | ៦៥ | ២២ | ៧១ | ៤៩ | ២២ |
| ពស់ចឹក | ១០ | ៨ | ២ | ២ | ២ | ០ |
| ឃាតកម្ម | ២៧ | ១៩ | ៨ | ១១ | ៧ | ៤ |
| ផ្សេងៗ | ៣៨៩ | ១៩៩ | ១៩០ | ២២៧ | ១៣០ | ៩៧ |
| **សរុបរួម** | **៥.១៩៣** | **២.៨១៧** | **២.៣៧៦** | **៤.៨០៦** | **២.៥៣៤** | **២.២៧២** |

តារាងទី(៦) បានបង្ហាញថា៖ រយៈពេល១២ខែកន្លងមក ចំនួនអ្នកស្លាប់សរុបនៅក្នុង**ខេត្តកណ្តាល**មាន ៥.១៩៣នាក់ (ស្រី ២.៣៧៦នាក់) ក្នុងនោះអ្នកស្លាប់ដោយសារជំងឺមានចំនួន ៤.២៤២នាក់ (ស្រី ២.០៥១នាក់) ដោយគ្រោះថ្នាក់ចរាចរណ៍មាន ៤៣៨នាក់ (ស្រី ១០៣នាក់) ដោយលង់ទឹកមាន ៨៧នាក់ (ស្រី ២២នាក់) ដោយពស់ចឹកមាន ១០នាក់ (ស្រី ២នាក់) ដោយឃាតកម្មមាន ២៧នាក់ (ស្រី ៨នាក់) និងស្លាប់ដោយសារមូលហេតុផ្សេងៗទៀតមាន ៣៨៩នាក់ (ស្រី ១៩០នាក់)។ **ខេត្តតាកែវ**មាន ៤.៨០៦នាក់ (ស្រី ២.២៧២នាក់) ក្នុងនោះអ្នកស្លាប់ដោយសារ

ជំងឺមានចំនួន ៤.២១៧នាក់ (ស្រី ២.០៨៣នាក់) ដោយគ្រោះថ្នាក់ចរាចរណ៍មាន ២៧៨នាក់ (ស្រី ៦៦នាក់) ដោយលង់ទឹកមាន ៧១នាក់ (ស្រី ២២នាក់) ដោយពស់ចឹកមាន ២នាក់ (ស្រី ០នាក់) ដោយឃាតកម្មមាន ១១នាក់ (ស្រី ៤នាក់) និងស្លាប់ដោយសារមូលហេតុផ្សេងៗទៀតមាន ២២៧នាក់ (ស្រី ៩៧នាក់)។

## ខ. ភាគរយនៃការស្លាប់

*រូបទី (១៧) ភាគរយចម្បងនៃការស្លាប់រយៈពេល១២ខែកន្លងមក*




រូបទី(១៧) បានបង្ហាញថា៖ អ្នកស្លាប់សរុបមាន ៥.១៩៣នាក់ នៅ**ខេត្តកណ្ដាល** ក្នុងនោះ អ្នកស្លាប់ដោយសារជំងឺមានខ្ពស់ជាងគេគឺរហូតដល់ ៨១,៦៩% ខណៈដែលអ្នកស្លាប់ដោយសារពស់ចឹកមានទាបជាងគេបំផុតគឺត្រឹមតែ ០,១៩% ប៉ុណ្ណោះ។ ចំណែកនៅ**ខេត្តតាកែវ** មានចំនួនអ្នកស្លាប់សរុប ៤.៨០៦នាក់ ក្នុងនោះយើងសង្កេតឃើញថា អ្នកស្លាប់ដោយសារជំងឺក៏មានខ្ពស់ជាងគេដែរ គឺរហូតដល់ ៨៧,៧៥% ខណៈដែលអ្នកស្លាប់ដោយ សារពស់ចឹកមានទាបជាងគេបំផុតគឺត្រឹមតែ ០,០៤% ប៉ុណ្ណោះ។

### គ. ភេទនៃអ្នកស្លាប់

រូបទី(១៨) បានបង្ហាញថា៖ នៅ**ខេត្តកណ្តាល**មានអ្នកស្លាប់សរុប ៥.១៩៣នាក់ ដែលក្នុងនោះអ្នកស្លាប់ភេទប្រុសមានចំនួន ៥៤,២៥% និងអ្នកស្លាប់ភេទស្រីមានចំនួន ៤៥,៧៥% ស្របពេលដែល **ខេត្តតាកែវ** មានចំនួនអ្នកស្លាប់សរុប ៤.៨០៦នាក់ ដែលក្នុងនោះអ្នកស្លាប់ភេទប្រុសមានចំនួន ៥២,៧៣% និងអ្នកស្លាប់ភេទស្រីមានចំនួន ៤៧,២៧%។ សរុបសេចក្តីមក នៅក្នុងខេត្តទាំងពីរនេះភាគរយនៃមនុស្សប្រុសមានការស្លាប់ច្រើនជាងភាគរយនៃមនុស្សស្រី។

*រូបទី(១៨) ភាគរយអ្នកស្លាប់នៅរយៈពេល១២ខែកន្លងមកតាមភេទ*




### ឃ. ការស្លាប់នៃកុមារអាយុក្រោម៥ឆ្នាំ

រូបទី(១៩) បានបង្ហាញថា៖ ក្នុងរយៈពេល១២ខែកន្លងមកនេះ ដោយផ្អែកលើតារាងទី(៦) ខាងលើយើងឃើញថា នៅក្នុងខេត្តទាំង២ (កណ្តាល និងតាកែវ) មានអ្នកស្លាប់សរុបចំនួន ៩៩៩៩នាក់ ក្នុងនោះមាន ១,៦% ជាកុមារអាយុក្រោម៥ឆ្នាំនៅក្នុងខេត្តកណ្តាល និង ៣,៤% ជាកុមារអាយុក្រោម៥ឆ្នាំនៅក្នុងខេត្តតាកែវ។

*រូបទី(១៩) ភាគរយនៃកុមារអាយុក្រោម៥ឆ្នាំស្លាប់រយៈពេល១២ខែកន្លងមក*



## ២.៣. ពិការភាព

*តារាងទី(៧) ពិការភាពនៃបុគ្គល*

| បរិយាយ | កណ្ដាល | តាកែវ |
|---|---|---|
| បុគ្គលដែលរងគ្រោះដោយសារគ្រាប់មីន | ៣៤៦ | ២៦៧ |
| មនុស្សចាស់ដែលគ្មានអ្នកមើលថៃ | ៤៩៧ | ៥៨០ |
| អនីតិជនដែលពិការ (អាយុក្រោម១៨ឆ្នាំ) | ១.២៣៤ | ៨០៦ |
| បុគ្គលពិការដែលមានប្រភពចំណូល | ១.៤០៥ | ១.៣០៧ |
| បុគ្គលពិការដែលគ្មានចំណូល | ១.៩៦៧ | ១.៨៩១ |

### ក. ការរងគ្រោះដោយសារគ្រាប់មីន

*រូបទី(២០) ភាគរយបុគ្គលដែលរងគ្រោះដោយសារគ្រាប់មីន*




រូបទី(២០) បានបង្ហាញថាៈ នៅ**ខេត្តកណ្ដាល**មានជនរងគ្រោះដោយសារគ្រាប់មីនសរុបចំនួន ៣៤៦នាក់ ដែលក្នុងនោះមានចំនួន ៨២,៦៦% ជាមនុស្សប្រុស និង ១៧,៣៤% ជាមនុស្សស្រី។ ទន្ទឹមនោះ **ខេត្តតាកែវ** មានជនរងគ្រោះដោយសារគ្រាប់មីនសរុបចំនួន ២៦៧នាក់ ដែលក្នុងនោះមានចំនួន ៨៨,៧៦% ជាមនុស្សប្រុស និង ១១,២៤% ជាមនុស្សស្រី។ សរុបសេចក្ដីមក នៅក្នុងខេត្តទាំងពីរនេះ ភាគរយនៃមនុស្សប្រុសមានការរងគ្រោះដោយសារគ្រាប់មីនច្រើនជាងភាគរយនៃមនុស្សស្រី។

## ខ. មនុស្សចាស់គ្មានអ្នកមើលថែ ឬគ្រួសារផ្គត់ផ្គង់

*រូបទី(២១) ភាគរយមនុស្សចាស់ដែលគ្មានអ្នកមើលថែឬគ្រួសារផ្គត់ផ្គង់*




រូបទី(២១) បានបង្ហាញថា៖ នៅ**ខេត្តកណ្តាល**មានមនុស្សចាស់ដែលគ្មានអ្នកមើលថែ ឬគ្រួសារផ្គត់ផ្គង់សរុបចំនួន ៤៩៧នាក់ ដែលក្នុងនោះមានចំនួន ៧៧,០៦% ជាមនុស្សស្រី និង ២២,៩៤% ជាមនុស្សប្រុស។ ទន្ទឹមនោះ **ខេត្តតាកែវ** មានមនុស្សចាស់ដែលគ្មានអ្នកមើលថែ ឬគ្រួសារផ្គត់ផ្គង់សរុបចំនួន ៥៨០នាក់ ដែលក្នុងនោះមានចំនួន ៧៩,៣១% ជាមនុស្សស្រី និង ២០,៦៩% ជាមនុស្សប្រុស។ សរុបសេចក្តីមក នៅក្នុងខេត្តទាំងពីរនេះភាគរយនៃមនុស្សចាស់ដែលគ្មានអ្នកមើលថែ ឬគ្រួសារផ្គត់ផ្គង់ជាស្ត្រីមានចំនួនច្រើនជាងភាគរយនៃបុរស។

## គ. ពិការភាពនៃអនីតិជន (អាយុក្រោម១៨ឆ្នាំ)

*រូបទី(២២) ភាគរយពិការភាពនៃអនីតិជន(អាយុក្រោម១៨ឆ្នាំ*




ឆ្នាំ) សរុបចំនួន ១.២៣៤នាក់ ដែលក្នុងនោះមានចំនួន ៥១,៦២% ជាមនុស្សប្រុស និង ៤៨,៣៨% ជាមនុស្សស្រី។ ទន្ទឹមនោះដែរ **ខេត្តតាកែវ** មានពិការភាពនៃអនីតិជន (អាយុក្រោម១៨ឆ្នាំ) សរុប

ចំនួន ៨០៦នាក់ ដែលក្នុងនោះមានចំនួន ៥១,៩៩% ជាមនុស្សប្រុស និង ៤៨,០១% ជាមនុស្សស្រី។ សរុបសេចក្តីមក នៅក្នុងខេត្តទាំងពីរនេះភាគរយពិការភាពនៃអនីតិជន (អាយុក្រោម១៨ឆ្នាំ)ជាមនុស្សប្រុសច្រើនជាងភាគរយនៃមនុស្សស្រី។

### ឃ. ប្រភពចំណូលនៃបុគ្គលពិការភាព

*រូបទី(២៣) ភាគរយប្រភពចំណូលនៃបុគ្គលពិការភាព*




រូបទី(២៣) បានបង្ហាញថា៖ **ខេត្តកណ្តាល** មានបុគ្គលពិការភាពសរុបចំនួន ៣.៣៧២នាក់ ដែលក្នុងនោះមាន ៥៨,៣៣% មានប្រភពប្រាក់ចំណូល (អាចរកប្រាក់ចំណូលដោយខ្លួនឯងបាន ដូចជាធ្វើជាជាងកាត់សក់ អ៊ុតសក់ កែសម្ភស្សជាដើម) និង ៤១,៦៧% គ្មានប្រភពប្រាក់ចំណូល (មិនអាចប្រកបរបររកស៊ីអ្វីបាន ពឹងលើអ្នកសាច់ញាតិ ឬអ្នកដទៃចិញ្ចឹម)។ **ខេត្តតាកែវ** មានបុគ្គលពិការភាពសរុបចំនួន ៣.១៩៨នាក់ ដែលក្នុងនោះមាន ៥៩,១៣% មានប្រភពប្រាក់ចំណូល និង ៤០,៨៧% គ្មានប្រភពប្រភពប្រាក់ចំណូល។

### ង. ផ្ទៃដីសំអាតគ្រាប់មីន(គិតជាហិកតា)

*រូបទី(២៤) ផ្ទៃដីដែលបានសំអាតគ្រាប់មីន(គិតជាហិកតា)*



រូបទី(២៤) បានបង្ហាញថា៖ ចំនួនផ្ទៃដីដែលបានសំអាតគ្រាប់មីនសរុបមាន ១.៧៩២ហិកតា នៅខេត្តកណ្តាល និង ៥៦៣ហិកតា នៅក្នុងខេត្តតាកែវ។

## ២.៤. ការប្រើប្រាស់ទឹក និងអនាម័យ

***តារាងទី(៨)ប្រភពទឹកប្រើប្រាស់ និងអនាម័យតាមគ្រួសារ***

| បរិយាយ | កណ្តាល | តាកែវ |
|---|---|---|
| គ្រួសារដែលទទួលបានទឹកស្អាតបរិភោគ( ទុយោ ) | ១៨០,៥២៣ | ៥៨,៥៥៧ |
| គ្រួសារដែលប្រើប្រាស់ទឹកអណ្តូងសម្រាប់បរិភោគ | ៤២,៩៣៥ | ៦៤,៥៤៨ |
| គ្រួសារប្រើប្រាស់ទឹកភ្លៀងសម្រាប់បរិភោគ | ៤០,០៦៦ | ៣៦,១៩៧ |
| គ្រួសារបានប្រើប្រាស់ទឹកស្រះ /បឹង/ស្ទឹង/ទន្លេ សម្រាប់បរិភោគ | ២២,៦៥១ | ៧០,១០២ |
| គ្រួសារមានបង្គន់អនាម័យផ្ទាល់ខ្លួន | ២៣២,៩៨៦ | ១៦៥,១៦៨ |

### ក. ការប្រើប្រាស់ទឹក

*រូបទី(២៥) ភាគរយនៃការប្រើប្រាស់ទឹករបស់គ្រួសារ*



រូបទី(២៥) បានបង្ហាញថា៖ **ខេត្តកណ្តាល** នៅក្នុងគ្រួសារសរុប ២៨៦.១៧៥គ្រួសារ មានគ្រួសារដែលទទួលបានទឹកស្អាតបរិភោគ(ទុយោ) ៦៣,០៨% គ្រួសារដែលប្រើប្រាស់ទឹកអណ្តូងសម្រាប់បរិភោគ (១៥%) គ្រួសារប្រើប្រាស់ទឹកភ្លៀងសម្រាប់បរិភោគ ១៤% និងគ្រួសារបានប្រើប្រាស់ទឹកស្រះ/បឹង/ស្ទឹង/ទន្លេ សម្រាប់បរិភោគ ៧,៩២% រីឯ**ខេត្តតាកែវ** នៅក្នុងគ្រួសារសរុប ២២៩.៤០៤គ្រួសារ មានគ្រួសារដែលទទួលបានទឹកស្អាតបរិភោគ(ទុយោ) ២៥,៥៣% គ្រួសារដែលប្រើប្រាស់ទឹកអណ្តូងសម្រាប់បរិភោគ (២៨,១៣%) គ្រួសារប្រើប្រាស់ទឹកភ្លៀងសម្រាប់បរិភោគ ១៥,៧៨% និងគ្រួសារបានប្រើប្រាស់ទឹកស្រះ/បឹង/ស្ទឹង/ទន្លេ សម្រាប់បរិភោគ ៣០,៥៦%។

## ខ. អនាម័យ




រូបទី(២៦) បានបង្ហាញថា៖ នៅក្នុងចំណោមគ្រួសារសរុប ២៨៦.១៧៥គ្រួសារ នៃ**ខេត្តកណ្តាល** មាន ៨១,៤១% ជាគ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់ផ្ទាល់ខ្លួន ចំណែក**ខេត្តតាកែវ** មានគ្រួសារសរុប ២២៩.៤០៤គ្រួសារ ក្នុងនោះមាន ៧២% ជាគ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់ផ្ទាល់ខ្លួន។ យើងឃើញថា ខេត្តទាំងពីរមានបង្គន់អនាម័យច្រើនគួរសម តែក៏មិនទាន់គ្រប់ចំនួនដែលត្រូវប្រកាសថាជា "**ខេត្តឈប់បន្ទោរបង់ពាសវាលពាលកាល** (ODF)" នៅឡើយ។ ដូច្នោះ អង្គភាពដែលពាក់ព័ន្ធ ពិសេសអង្គភាពនៅមូលដ្ឋានគួរតែបន្តជម្រុញបន្ថែមទៀតដល់ប្រជាពលរដ្ឋអំពីបញ្ហានេះ។

### គ. គ្រួសារគ្មានផ្ទះសំបែង

*រូបទី(២៧) ភាគរយគ្រួសារដែលរស់នៅលើដីសាធារណៈ និងគ្មានផ្ទះសំបែង*




រូបទី(២៧) បានបង្ហាញថាៈ ក្នុងចំណោមគ្រួសារសរុប ២៨៦.១៧៥គ្រួសារ នៅក្នុង**ខេត្តកណ្តាល** មាន ៣,៥% ជាគ្រួសារដែលរស់នៅលើដីសាធារណៈ និង ០,៧% ជាគ្រួសារដែលគ្មានផ្ទះសម្បែង។ **ខេត្តតាកែវ** មានគ្រួសារសរុប ២២៩.៤០៤គ្រួសារ ក្នុងនោះមាន ០,៦% ជាគ្រួសារដែលរស់នៅលើដីសាធារណៈ និង ០,៤% ជាគ្រួសារដែលគ្មានផ្ទះសម្បែង។

## ២.៥. បរិស្ថាន និងធនធានធម្មជាតិ

### ក. ផ្ទៃដីចោលសំរាម

*រូបទី(២៨) ផ្ទៃដីសម្រាប់ចោលសំរាម (គិតជាហិកតា)*



រូបទី(២៨) បានបង្ហាញពីផ្ទៃដីសម្រាប់ចោលសំរាមដែលមាននៅក្នុងទាំងពីរ ដែលក្នុងនោះ **ខេត្តកណ្តាល**មាន ៧៧ហិកតា និង**ខេត្តតាកែវ**មាន ៨២ហិកតា។

## ខ. ផ្ទៃដីចោលកាកសំណល់ឧស្សាហកម្ម

*រូបទី(២៩) ផ្ទៃដីសម្រាប់ចោលកាកសំណល់ឧស្សាហកម្ម (គិតជាហិកតា)*




រូបទី(២៩) បានបង្ហាញពីផ្ទៃដីសម្រាប់ចោលកាកសំណល់ឧស្សាហកម្មដែលមាននៅក្នុងទាំងពីរ ដែលក្នុងនោះ **ខេត្តកណ្តាល**មាន ៧ហិកតា និង**ខេត្តតាកែវ**មាន ១១ហិកតា។

## គ. ផ្ទៃដីរោងចក្រ

*រូបទី(៣០) ផ្ទៃដីសម្រាប់រោងចក្រ (គិតជាហិកតា)*




រូប(៣០) បានបង្ហាញពីក្រលាផ្ទៃដីទីតាំងរោងចក្រ ក្នុងនោះខេត្តបន្ទាយមានជ័យ ២៥ហិកតា ខេត្តបាត់ដំបង ៣៦ហិកតា ខេត្តកំពង់ឆ្នាំង ៨៤ហិកតា ខេត្តកំពង់ស្ពឺ ៤៤៨ហិកតា និង ពោធិ៍សាត់មិនមាន។

## ឃ. ការចម្អិនអាហារ

*រូបទី(៣១) ភាគរយនៃគ្រួសារដែលប្រើប្រាស់អុស/ធ្យូងសម្រាប់ចម្អិន*




រូបទី(៣១) បានបង្ហាញថា៖ ក្នុងចំណោមគ្រួសារសរុប ២៨៦.១៧៥គ្រួសារ នៅក្នុង**ខេត្តកណ្តាល** មាន ៣១,៦៧% ជាគ្រួសារដែលប្រើប្រាស់អុស/ធ្យូងសម្រាប់ចម្អិនអាហារ ឯ**ខេត្តតាកែវ** មានគ្រួសារសរុប ២២៩.៤០៤គ្រួសារ ក្នុងនោះមាន ៣៦,៣៣% ជាគ្រួសារដែលប្រើប្រាស់អុស/ធ្យូងសម្រាប់ចម្អិនអាហារ។

## ង. ធនធានធម្មជាតិ

***តារាងទី(៩) ធនធានធម្មជាតិ***

| បរិយាយ | កណ្តាល | តាកែវ |
|---|---|---|
| ព្រៃឈើគ្របដណ្តប់ | ១១៥ | ៩២ |
| ការដាំកូនឈើ | ២១៥ | ៤១២ |
| ការកាប់ឆ្ការព្រៃ | ៨៦ | ២៥ |

តារាងទី(៩) បានបង្ហាញឲ្យដឹងថា៖ **ខេត្តកណ្តាល** មានផ្ទៃដីព្រៃឈើគ្របដណ្តប់ចំនួន ១១៥ហិកតា ការដាំកូនឈើ ២១៥ហិកតា និងការកាប់ឆ្ការព្រៃ ៨៦ហិកតា។ **ខេត្តតាកែវ** មានផ្ទៃដីព្រៃឈើគ្របដណ្តប់ចំនួន ៩២ហិកតា ការដាំកូនឈើ ៤១២ហិកតា និងការកាប់ឆ្ការព្រៃចំនួន ២៥ហិកតា។

## ២.៦. គ្រោះធម្មជាតិ

### ក. គ្រួសាររងផលប៉ះពាល់ដោយគ្រោះធម្មជាតិ

*តារាងទី(១០) គ្រួសារដែលមានផលប៉ះពាល់ដោយគ្រោះធម្មជាតិ*

| គ្រោះ ធម្មជាតិ | ទឹកជំនន់ | ដីបាក់ឬស្រុត | គ្រោះ រាំងស្ងួត | ខ្យល់ ព្យុះ/ខ្យល់ កន្ត្រាក់ |
|---|---|---|---|---|
| កណ្ដាល | ៧៧៩ | ៦១៧ | ៤,៥០៧ | ១៧៦ |
| តាកែវ | ៤៦១ | 0 | ១,១៥០ | ៣៨៣ |

តារាងទី(១០) បានបង្ហាញឲ្យដឹងពីចំនួនគ្រួសារដែលមានផលប៉ះពាល់ដោយសារគ្រោះធម្មជាតិ ដែលរួមមាន៖ **ខេត្តកណ្ដាល** រងគ្រោះដោយទឹកជំនន់៧៧៩គ្រួសារ ដីបាក់ឬស្រុត៦១៧គ្រួសារ គ្រោះរាំងស្ងួត៤.៥០៧គ្រួសារ និងខ្យល់ព្យុះ/ខ្យល់កន្ត្រាក់១៧៦គ្រួសារ។ **ខេត្តតាកែវ** រងគ្រោះដោយទឹកជំនន់៤៦១គ្រួសារ គ្រោះរាំងស្ងួត១.១៥០គ្រួសារ និងខ្យល់ព្យុះ/ខ្យល់កន្ត្រាក់៣៨៣គ្រួសារ។

### ខ. ផ្ទៃដីរងផលប៉ះពាល់ដោយគ្រោះធម្មជាតិ

*តារាងទី(១១) ផ្ទៃដីដែលមានផលប៉ះពាល់ដោយគ្រោះធម្មជាតិ (គិតជាហិកតា)*

| គ្រោះ ធម្មជាតិ | ទឹកជំនន់ | ដីបាក់ឬស្រុត | គ្រោះ រាំងស្ងួត | ខ្យល់ ព្យុះ/ខ្យល់ កន្ត្រាក់ |
|---|---|---|---|---|
| កណ្ដាល | ៤០៤ | ៦,៥៣០ | ១,៩៨៤ | ១,១៥៥ |
| តាកែវ | ១៥៤ | 0 | ៦៥៣ | ១០៨ |

តារាងទី(១១) បានបង្ហាញឲ្យដឹងពីចំនួនផ្ទៃដីដែលមានផលប៉ះពាល់ដោយសារគ្រោះធម្មជាតិ ដែលរួមមាន៖ **ខេត្តកណ្ដាល** រងគ្រោះដោយទឹកជំនន់៤០៤ហិកតា ដីបាក់ឬស្រុត៦.៥៣០ហិកតា គ្រោះរាំងស្ងួត១.៩៨៤ហិកតា និងខ្យល់ព្យុះ/ខ្យល់កន្ត្រាក់១.១៥៥ហិកតា។ **ខេត្តតាកែវ** រងគ្រោះដោយទឹកជំនន់១៥៤ហិកតា គ្រោះរាំងស្ងួត៦៥៣ហិកតា និងខ្យល់ព្យុះ/ខ្យល់កន្ត្រាក់១០៨ហិកតា។

## ២.៧. សន្តិសុខសង្គម និងសេដ្ឋកិច្ច

### ២.៧.១. អសន្តិសុខសង្គម

បញ្ហាអសន្តិសុខសង្គមសំដៅលើការលួច ឆក់ ប្លន់ ចាប់ជម្រិត ឧក្រិដ្ឋកម្ម ប្រើប្រាស់គ្រឿងញៀន និងជម្លោះដីធ្លីនៅក្នុងមូលដ្ឋានជាដើម។ ចំពោះករណីទាំងអស់នោះ ទោះបីជាមានចំនួនកើតឡើងច្រើនយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាលខិតខំដោះស្រាយបានមួយចំនួនធំដែរ ដូចមានតួលេខបានបញ្ជាក់ដូចខាងក្រោមនេះ៖

#### ក. ករណីលួច និងឆក់

*រូបទី(៣២) ករណីលួច និងឆក់*




រូបទី(៣២) បានបង្ហាញថា៖ **ខេត្តកណ្តាល** មានករណីលួច និងឆក់ចំនួន ៤៥៧ករណី ក្នុងនោះបានដោះស្រាយចំនួន ២២០ករណី ចំណែកឯ**ខេត្តតាកែវ** មានករណីទាំងនេះកើតឡើងចំនួន ៤២៦ករណី ក្នុងនោះបានដោះស្រាយសរុប ១៧៧ករណី។

#### ខ. ករណីឃាតកម្ម ប្លន់ ចាប់ជម្រិត និងឧក្រិដ្ឋកម្ម

*រូបទី(៣៣) ករណីឃាតកម្ម ប្លន់ និងចាប់ជម្រិត និងឧក្រិដ្ឋកម្ម*



រូបទី(៣៣) បានបង្ហាញថា៖ **ខេត្តកណ្តាល** មានករណីឃាតកម្ម ប្លន់ ចាប់ជម្រិត និងឧក្រិដ្ឋកម្មចំនួន ២៤ករណី ក្នុងនោះបានដោះស្រាយចំនួន ១៩ករណី ចំណែកឯ**ខេត្តតាកែវ** មានករណីទាំងនេះកើតឡើងចំនួន ២៩ករណី ក្នុងនោះបានដោះស្រាយសរុប ២០ករណី។

## គ. ជម្លោះដីធ្លី

*រូបទី(៣៤) ករណីជម្លោះដីធ្លី*




រូបទី(៣៤) បានបង្ហាញថា៖ **ខេត្តកណ្តាល** មានករណីជម្លោះដីធ្លីចំនួន ៩២១ករណី ក្នុងនោះបានដោះស្រាយចំនួន ៦១៤ករណី ចំណែកឯ**ខេត្តតាកែវ** មានករណីនេះកើតឡើងចំនួន ១.១២៧ ករណី ក្នុងនោះបានដោះស្រាយសរុប ៨៨២ករណី។

## ឃ. ការឈ្លោះទាស់ទែងគ្នារបស់ប្រជាពលរដ្ឋ

*រូបទី(៣៥) ករណីប្រជាពលរដ្ឋឈ្លោះទាស់ទែងគ្នា*



រូបទី(៣៥) បានបង្ហាញថា៖ **ខេត្តកណ្ដាល** មានករណីប្រជាពលរដ្ឋឈ្លោះទាស់ទែងគ្នាចំនួន ១.៤៩១ករណី ក្នុងនោះបានដោះស្រាយចំនួន ១.៣១៧ករណី ចំណែកឯ**ខេត្តតាកែវ** មានករណីនេះកើតឡើងចំនួន ១.២៧៤ករណី ក្នុងនោះបានដោះស្រាយសរុប ១.០៥៩ករណី។

## ង. អំពើហិង្សាក្នុងគ្រួសារ និងគ្រឿងញៀន

*រូបទី(៣៦) ភាគរយអំពើហិង្សាក្នុងគ្រួសារ និងគ្រឿងញៀន*




រូប(៣៦)បានបង្ហាញថា៖ ចំណោមគ្រួសារនៅ**ខេត្តកណ្ដាល** ១.០០០គ្រួសារ មាន៣គ្រួសារជួបអំពើហិង្សាក្នុងគ្រួសារ និង៨គ្រួសារប្រើប្រាស់គ្រឿងញៀន ចំណែក**ខេត្តតាកែវ** ចំណោម ១.០០០គ្រួសារ មាន៥គ្រួសារជួបអំពើហិង្សាក្នុងគ្រួសារ និង១២គ្រួសារបានប្រើប្រាស់គ្រឿងញៀន។

## ច. ស្ត្រីរងគ្រោះដោយការចាប់រំលោភ និងជួញដូរ

*រូបទី(៣៧) ករណីស្ត្រីរងគ្រោះដោយសារការចាប់រំលោភ និងជួញដូរ*



រូបទី(៣៧) បានបង្ហាញថា៖ **ខេត្តកណ្ដាល** មានស្ត្រីរងគ្រោះចំនួន៣៣ករណី (ការចាប់រំលោភ២៨ករណី និងជួញដូរ៥ករណី) **ខេត្តតាកែវ** មានស្ត្រីរងគ្រោះចំនួន១៤ករណី (ការចាប់រំលោភ៨ករណី និងជួញដូរ៦ករណី)។

## ២.៧.២. សេដ្ឋកិច្ចគ្រួសារ

រូបទី(៣៨) បានបង្ហាញពីសកម្មភាពអាជីវកម្មចម្បងរបស់គ្រួសារក្រៅពីរបរកសិកម្ម ដែល៖ **ខេត្តកណ្ដាល** មាន ១៧.៣០៥គ្រួសារ និង**ខេត្តតាកែវ** មានចំនួន ១៦.៨២០គ្រួសារ។

*រូបទី(៣៨) ចំនួនគ្រួសារមានសកម្មភាពអាជីវកម្ម*




### ក. ផ្នែកម៉ាស៊ីនកិនស្រូវ

*រូបទី(៣៩) ចំនួនគ្រួសារមានអាជីវកម្មម៉ាស៊ីនកិនស្រូវ*



សកម្មភាពអាជីវកម្មម៉ាស៊ីនកិនស្រូវ (រូបទី៣៩) បានបង្ហាញថាៈ **ខេត្តកណ្តាល** មានចំនួន ៧៣៨គ្រួសារ និង**ខេត្តតាកែវ** មានចំនួន ២.៦០៨គ្រួសារ។

## ខ. ផ្នែកសណ្ឋាគារ ផ្ទះសំណាក់ និងភោជនីយដ្ឋាន

*រូបទី(៤០) ចំនួនគ្រួសារមានសណ្ឋាគារ ផ្ទះសំណាក់ និងភោជនីយដ្ឋាន*




សកម្មភាពអាជីវកម្មសណ្ឋាគារ ផ្ទះសំណាក់ និងភោជនីយដ្ឋាន (រូបទី៤០) បានបង្ហាញថាៈ **ខេត្តកណ្តាល** មានចំនួន ៣៦៦គ្រួសារ និង**ខេត្តតាកែវ** មានចំនួន ២០៤គ្រួសារ។

## គ. ផ្នែកជួសជុលគ្រឿងម៉ាស៊ីន

*រូបទី(៤១) ចំនួនគ្រួសារមានអាជីវកម្មជួសជុលគ្រឿងម៉ាស៊ីនគ្រប់ប្រភេទ*




សកម្មភាពអាជីវកម្មជួសជុលគ្រឿងម៉ាស៊ីនគ្រប់ប្រភេទ (រូបទី៤១) បានបង្ហាញថាៈ **ខេត្តកណ្តាល** មានចំនួន ៣.០៥៤គ្រួសារ និង**ខេត្តតាកែវ** មានចំនួន ២.១៩៣គ្រួសារ។

### ឃ. ផ្នែកគ្រឿងសំណង់ និងសង្ហារឹម




សកម្មភាពអាជីវកម្មលក់គ្រឿងសំណង់និងសង្ហារឹម (រូបទី៤២) បានបង្ហាញថា៖ **ខេត្តកណ្ដាល** មានចំនួន ៨៧៤គ្រួសារ និង**ខេត្តតាកែវ** មានចំនួន ៥៨១គ្រួសារ។

### ង. ផ្នែកគ្រឿងទេស ភេសជ្ជៈ ថ្នាំពេទ្យ និងគ្លីនិក




សកម្មភាពអាជីវកម្មលក់គ្រឿងទេសនិងភេសជ្ជៈ ថ្នាំពេទ្យ និងគ្លីនិក (រូបទី៤៣) បានបង្ហាញថា៖ **ខេត្តកណ្ដាល** មានចំនួន ៤.១៤២គ្រួសារ និង**ខេត្តតាកែវ** មានចំនួន ៤.៧៨៣គ្រួសារ។

### ច. ផ្នែកស្ថានីយ៍ប្រេងឥន្ធនៈ

*រូបទី(៤៤) ចំនួនគ្រួសារមានអាជីវកម្មស្ថានីយ៍ប្រេងឥន្ធនៈ*




សកម្មភាពអាជីវកម្មលើផ្នែកស្ថានីយ៍ប្រេងឥន្ធនៈគ្រប់កម្រិត (រូបទី៤៤) បានបង្ហាញថា៖ **ខេត្តកណ្ដាល** មានចំនួន ៣.៩៤៧គ្រួសារ និង**ខេត្តតាកែវ** មានចំនួន ៣.៧២០គ្រួសារ។

### ឆ. ផ្នែកបិតស្រា

*រូបទី(៤៥) ចំនួនគ្រួសារមានអាជីវកម្មបិតស្រា*




សកម្មភាពអាជីវកម្មបិតស្រា (រូបទី៤៥) បានបង្ហាញថា៖ **ខេត្តកណ្ដាល** មានចំនួន ៥៥០គ្រួសារ និង**ខេត្តតាកែវ** មានចំនួន ៧៦៧គ្រួសារ។

### ជ. ផ្នែកកែសម្ផស្ស

*រូបទី(៤៦) ចំនួនគ្រួសារមានអាជីវកម្មកាត់សក់ អ៊ុតសក់ និងកែសម្ផស្ស*




សកម្មភាពអាជីវកម្មកាត់សក់ អ៊ុតសក់ និងកែសម្ផស្ស (រូបទី៤៦) បានបង្ហាញថាៈ **ខេត្តកណ្តាល** មានចំនួន ១.៦៨០គ្រួសារ និង**ខេត្តតាកែវ** មានចំនួន ១.០៨២គ្រួសារ។

### ឈ. ផ្នែកកាត់កញ្ចក់ និងដែក

*រូបទី(៤៧) ចំនួនគ្រួសារមានអាជីវកម្មកាត់កញ្ចក់ និងជាងដែក*




សកម្មភាពអាជីវកម្មកាត់កញ្ចក់ និងជាងដែក (រូបទី៤៧) បានបង្ហាញថាៈ **ខេត្តកណ្តាល** មានចំនួន ៥១៤គ្រួសារ និង**ខេត្តតាកែវ** មានចំនួន ៤៩៤គ្រួសារ។

## ៣. ផ្នែកផ្សេងៗទៀត

*រូបទី(៤៨) ចំនួនគ្រួសារមានអាជីវកម្មផ្សេងៗទៀត*




រូបទី(៤៨) បានបង្ហាញថា៖ ក្រៅពីផ្នែកអាជីវកម្មទាំង៩ខាងលើ ប្រជាពលរដ្ឋ**ខេត្តកណ្ដាល** ចំនួន ១.៤៤០គ្រួសារ និង**ខេត្តតាកែវ** ចំនួន ៣៨៨គ្រួសារ ទៀតបាននិងកំពុងប្រកបរបរអាជីវកម្មផ្សេងៗទៀត។

## ២.៧.៣. ប្រភេទនៃលំហូរវិនិយោគ

*រូបទី(៤៩) ចំនួនប្រភេទនៃសកម្មភាពអភិវឌ្ឍន៍*



លំហូរវិនិយោគតាមប្រភេទនៃសកម្មភាពអភិវឌ្ឍន៍ (រូបទី៤៩) បានបង្ហាញថា៖ **ខេត្តកណ្តាល** មានការអភិវឌ្ឍទៅលើហេដ្ឋារចនាសម្ព័ន្ធចំនួន ១៤៩លើក កសិកម្ម ១៤១លើក ធារាសាស្ត្រ ១៤០លើក ការដាំដុះ ១៤០លើក បសុសត្វ/បសុបក្សី ១៤០លើក និងផ្សេងៗទៀតចំនួន ៧០០លើក។ **ខេត្តតាកែវ** មានការអភិវឌ្ឍទៅលើហេដ្ឋារចនាសម្ព័ន្ធចំនួន ៣៥៩លើក កសិកម្ម ៣៥៨លើក ធារាសាស្ត្រ ៣៥៨លើក ការដាំដុះ ៣៥៨លើក បសុសត្វ/បសុបក្សី ៣៥៨លើក និងផ្សេងៗទៀតចំនួន ៣.៩៣៨លើក។

## ២.៨. វិស័យអប់រំ និងសេវាសង្គម

### ២.៨.១. ផ្នែកសិក្សាអប់រំ

នៅក្នុងផ្នែកសិក្សាអប់រំនៅក្នុងអត្ថបទនេះ គឺសំដៅលើចំនួន និងចម្ងាយពីទីតាំងភូមិទៅកន្លែងផ្តល់សេវាអប់រំដល់ប្រជាពលរដ្ឋនៅទូទាំង២ខេត្ត។ កន្លែងមត្តេយ្យសហគមន៍ សាលាមត្តេយ្យ សាលាបឋមសិក្សា សាលាអនុវិទ្យាល័យ វិទ្យាល័យ និងសាកលវិទ្យាល័យរដ្ឋ (ទាំងរដ្ឋ និងឯកជន)។

**ក. ចំនួនគ្រឹះស្ថានសិក្សា**

*រូបទី(៥០) ចំនួនគ្រឹះស្ថានតាមកម្រិតសិក្សា*




រូបទី(៥០) បានបង្ហាញពីចំនួនគ្រឹះស្ថានសិក្សាតាមកម្រិតលំដាប់លំដោយចាប់ពីមត្តេយ្យសិក្សារហូតដល់សាកលវិទ្យាល័យដូចជា៖ **ខេត្តកណ្តាល** មានមត្តេយ្យសិក្សាចំនួន ៥៣៣កន្លែង បឋមសិក្សា ៥៥២កន្លែង អនុវិទ្យាល័យ ៣០៥កន្លែង វិទ្យាល័យ ១៧៦កន្លែង និងសាកលវិទ្យាល័យចំនួន

២៣កន្លែង។ **ខេត្តតាកែវ** មានមត្តេយ្យសិក្សាចំនួន ៤៣៦កន្លែង បឋមសិក្សា ៤៧០កន្លែង អនុវិទ្យាល័យ ១២៨កន្លែង វិទ្យាល័យ ៦៧កន្លែង និងសាកលវិទ្យាល័យចំនួន ៣កន្លែង។

## ខ. ចំនួនគ្រឹះស្ថានសិក្សាតាមវិស័យ




រូបទី(៥១) បានបង្ហាញពីចំនួនគ្រឹះស្ថានសិក្សាទៅតាមវិស័យនីមួយៗដូចជា៖ **ខេត្តកណ្ដាល** មានគ្រឹះស្ថានសិក្សារបស់រដ្ឋចំនួន ១.៣៥៧កន្លែង ឯកជនចំនួន ១៣៤កន្លែង និងសាលាសហគមន៍ចំនួន ៩៨កន្លែង។ **ខេត្តតាកែវ** មានគ្រឹះស្ថានសិក្សារបស់រដ្ឋចំនួន ៩៥៧កន្លែង ឯកជនចំនួន ៧៤កន្លែង និងសាលាសហគមន៍ចំនួន ៧៣កន្លែង។

## គ. ចម្ងាយប៉ាន់ស្មានពីភូមិទៅគ្រឹះស្ថានសិក្សា



រូបទី(៥២) បានបង្ហាញពីចម្ងាយប៉ាន់ស្មានជាមធ្យមដែលគិតពីភូមិនីមួយៗរបស់ប្រជាពលរដ្ឋទៅដល់គ្រឹះស្ថានសិក្សា រួមមាន៖ **ខេត្តកណ្តាល** ចម្ងាយជាមធ្យមគិតពីភូមិទៅដល់មត្តេយ្យសិក្សាប្រហែល៣ ៦គីឡូម៉ែត្រ បឋមសិក្សាប្រហែល ៣៨គីឡូម៉ែត្រ អនុវិទ្យាល័យប្រហែល ២៨គីឡូម៉ែត្រ វិទ្យាល័យប្រហែល ១៥គីឡូម៉ែត្រ និងពីភូមិទៅសាកលវិទ្យាល័យប្រហែល ១៥គីឡូម៉ែត្រ។ **ខេត្តតាកែវ** ចម្ងាយជាមធ្យមគិតពីភូមិទៅដល់មត្តេយ្យសិក្សាប្រហែល ១៩គីឡូម៉ែត្រ បឋមសិក្សាប្រហែល ២១គីឡូម៉ែត្រ អនុវិទ្យាល័យប្រហែល ១៤គីឡូម៉ែត្រ វិទ្យាល័យប្រហែល ១០គីឡូម៉ែត្រ និងពីភូមិទៅសាកលវិទ្យាល័យប្រហែល ៣១គីឡូម៉ែត្រ។

## ២.៨.២. ផ្នែកសេវាសង្គម

### ក. ចម្ងាយប៉ាន់ស្មានពីភូមិទៅមន្ទីរពេទ្យមណ្ឌលសុខភាព និងគ្លីនិកឯកជន

*រូបទី(៥៣) ចម្ងាយប៉ាន់ស្មានពីភូមិទៅកន្លែងផ្តល់សេវាសុខភាព*




រូបទី(៥៣) បានបង្ហាញពីចម្ងាយប៉ាន់ស្មានជាមធ្យមដែលគិតពីភូមិនីមួយៗរបស់ប្រជាពលរដ្ឋទៅកន្លែងផ្តល់សេវាសុខភាព រួមមាន៖ **ខេត្តកណ្តាល** ចម្ងាយជាមធ្យមពីភូមិទៅដល់មន្ទីរពេទ្យរដ្ឋប្រវែង ប្រហែល ៨គីឡូម៉ែត្រ មណ្ឌលសុខភាពប្រហែល ១៦គីឡូម៉ែត្រ និងពីភូមិទៅគ្លីនិកឯកជនប្រហែល ១៣គីឡូម៉ែត្រ។ **ខេត្តតាកែវ** ចម្ងាយជាមធ្យមពីភូមិទៅដល់មន្ទីរពេទ្យរដ្ឋប្រវែងប្រហែល ១៧គីឡូម៉ែត្រ មណ្ឌលសុខភាពប្រហែល ១១គីឡូម៉ែត្រ និងពីភូមិទៅគ្លីនិកឯកជនប្រហែល ៩គីឡូម៉ែត្រ។

## ខ. ចម្ងាយប៉ាន់ស្មានពីភូមិទៅសហគមន៍ប្រើប្រាស់ទឹក ឬអណ្តូង




រូបទី(៥៥) បានបង្ហាញថា៖ **ខេត្តកណ្តាល** ចម្ងាយផ្លូវពីភូមិទៅសហគមន៍ប្រើប្រាស់ទឹក ឬអណ្តូងមានប្រវែងជាមធ្យម ២គីឡូម៉ែត្រ ឯ**ខេត្តតាកែវ** មានប្រវែងជាមធ្យមប្រហែល ៧គីឡូម៉ែត្រ។

